# រាជបណ្ឌិត្យសភាកម្ពុជា

## លទ្ធផលកិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៅខែតុលា ឆ្នាំ២០១៨

( ចងក្រងដោយ៖ RAC Media; ប្រភពឯកសារ៖ កជភខ )

### ១-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៨

ថ្ងៃពុធ ៩រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត ហ៊ាន សុខុម បានបន្តប្រជុំ ពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ចបានចំនួន០៥ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- ប្រធានក្រុមផ្នែកលក់<br>អ. sale team leader<br>បារ. chef d'équipe de vente | អ្នកដឹកនាំក្រុមអ្នកលក់ ដែលទទួលភារកិច្ចផ្ទាល់ពីប្រធានផ្នែកលក់ ដើម្បីធ្វើឱ្យសម្រេចបានគោលដៅការលក់ប្រចាំថ្ងៃនិងទទួលបានការពេញ ចិត្តពីអតិថិជន។ |
| ២- អ្នកឯកទេសផ្នែកលក់<br>អ. sale specialist<br>បារ. spécialiste de vente | អ្នកលក់ទំនិញផ្ទាល់ដែលមានចំណេះដឹងបច្ចេកទេសច្បាស់លាស់ អំពីផលិតផល។ |
| ៣- តំណាងផ្នែកលក់<br>អ. sale representative<br>បារ. représentant des ventes / représentant commercial | អ្នកទាក់ទងអតិថិជន ដែលមានសមត្ថភាពយល់នូវអ្វីដែលអ្នកទិញចង់បាន ពន្យល់នីតិវិធីនៃការទិញ និងធានាដល់ដំណើរការលក់ឱ្យបានរលូន។ |
| ៤- កិច្ចទីផ្សារ / ម៉ាឃិធីង<br>អ. marketing<br>បារ. marketing (m.) | សំណុំនៃសកម្មភាពបុគ្គល ស្ថាប័ន ឬក្រុមហ៊ុននានាក្នុងការបង្កើតតម្លៃ ការផ្សព្វផ្សាយ ការជំរុញ ការដោះដូរ និងការផ្តល់នូវអ្វីដែលមានប្រយោជន៍ដល់អតិថិជន ដៃគូ និង សង្គមទាំងមូល។ |
| ៥-កិច្ចទីផ្សារការី / ការីម៉ាឃិធីង<br>អ. marketer<br>បារ. marketeur (m.) | អ្នករៀបចំនិងអនុវត្តយុទ្ធនាការកិច្ចទីផ្សារ។ |

### ២-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨

ថ្ងៃអង្គារ ៧កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តម សូ មុយឃៀង បានបន្តប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការអក្សរសិល្ប៍បានចំនួន០៥ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **១- កាព្យស្នេហា**<br>អ. idyll<br>បារ. idylle (f.) | *កំណាព្យមួយបែបដែលកវីបាននិពន្ធឡើងដោយមានខ្លឹមសារទាក់ទងទៅនឹងស្នេហា ប្រុសស្រី ទេសភាព ធម្មជាតិ ជនបទ...។*<br>*ឧទាហរណ៍*<br>*-បងដើរមាត់ព្រែក ឮខ្មែកវាយឃំ*<br>*បងដើរជើងភ្នំ ឮឃ្មុំយកផ្កា។*<br><br>*-មើលដងទំនងព្រៃស្រងាត់ ដូចបងព្រាត់បាត់ពៅពិសី*<br>*ស្រក់ៗចិត្តប្រពន្ធប្តី នួនស្រីដូចស្រីស្រស់ឆោមឆាយ។*<br>*មើលភ្នំធំធេងវែងរលីក មើលទឹករលករលាមសាយ*<br>*មើលដីៗដុះវែងអន្លាយ មើលមេឃខ្ពស់ឆ្ងាយដូចឆ្ងាយស្នេហ៍ ។* |
| **២- កាព្យនាដ្យ ភាព**<br>អ. dramatic poetry<br>បារ. poésie dramatique (f.) | កំណាព្យមួយបែបដែលកវីបាននិពន្ធឡើងជារឿងរ៉ាវផ្សេងៗ ហើយអាចយក ទៅសម្តែងជារបាំឬល្ខោននៅលើឆាក ដើម្បីបង្កើតសិល្បបរិយាកាសដល់ អ្នកអាន អ្នកស្តាប់ និងអ្នកទស្សនា។<br>ឧទាហរណ៍ អត្ថបទកំណាព្យរឿងរាមកេរ្តិ៍។ |
| **៣- កាព្យវីរភេទ**<br>អ. epic poetry / epic<br>បារ. poésie épique / épopée | កំណាព្យមួយបែបដែលកវីបាននិពន្ធរៀបរាប់និទានយ៉ាងវែងអន្លាយពីតួអង្គវីរជនមានចិត្តតស៊ូអង់អាចក្លាហានមោះមុត ជាពិសេសក្នុងការធ្វើចម្បាំង ដើម្បីបម្រើនយោបាយឬឧត្តមគតិណាមួយ។<br>ឧទាហរណ៍ កំណាព្យរឿងរាមកេរ្តិ៍។<br>តាមរយៈសកម្មភាពរបស់តួអង្គកម្មការណ៍ :<br>(...) *គឺមោះអញកាន់ព្រះអាជ្ញា ព្រះបាទជេស្ឋា ធិរាជឥសូរអញនៃ។*<br>............... ................... ......................<br>*សូវស្លាប់អញពុំទៅជា ខ្ញុំព្រះរាមា ធិរាជនោះឡើយនេះឥឡូវ។*<br>*ចូរបាទៅទូលដោយនូវ បណ្តាំអញកូវ ធរេន្ទ្រធិរាជពីរអង្គ។*<br>*សូមស្តេចរណ្តាប់ពលផ្ទង់ ចេញកណ្តាលរើណរង្គ ប្រយុទ្ធដណ្តើមចេស្តា។(...)* |
| **៤- កាព្យប្រវត្តិសាស្ត្រ**<br>អ.Historical poetry<br>បារ.poésie historique | កំណាព្យមួយបែបដែលកវីនិពន្ធតាក់តែងឡើងដើម្បីពណ៌នាអំពីប្រវត្តិសាស្ត្រ ព្រឹត្តិការណ៍ណាមួយ ឬ វរជនណាមួយ។<br>ឧទាហរណ៍ សាស្ត្រារបាក្សត្រខ្មែរ។ |
| **៥- កាព្យពិពណ៌នា**<br>អ.descriptive poetry<br>បារ.poésie descriptive | កំណាព្យមួយបែបដែលកវីបាននិពន្ធឡើងដើម្បីរៀបរាប់អំពីមនុស្ស សត្វ ធម្មជាតិ ...។<br>ឧទាហរណ៍ ការពិពណ៌នាអំពីសម្រស់នាងកាកី ក្នុងរឿងកាកី :<br>(...) *ស្តេចមានមហេសី នាមកែវកាកី ល្អល្អះឥតហ្មង*<br>*ឥតមានស្រីណា សោភាផ្ទឹមផង សមសព្វកន្លង*<br>*កន្លោងអស់ស្រី។*<br>................... ................... ...................<br>*បើនរនៃអ្នក ណានឹងមិត្តភ័ក្តិ ចូល*<br>*ចងបេតី រួមរសស្នេហ៍ស្និទ្ធ ក្លិនជិតឥន្ទ្រិយ*<br>*ប្រាំពីរាត្រី*<br>*ទើបបាត់គន្ធា។ (...)* |

## ៣-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨

ថ្ងៃពុធ ៨កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម បានបន្តប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ចបានចំនួន០៥ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- កិច្ចទីផ្សារចម្រុះ/<br>ម៉ាឃិធីងចម្រុះ<br>អ. marketing mix<br>បារ. marketing mix ( m. ) | មធ្យោបាយកិច្ចទីផ្សារឬម៉ាឃិធីងទាំងឡាយដែលសហគ្រាសប្រើប្រាស់ ដើម្បីសម្រេចនូវការលក់ផលិតផលរបស់ខ្លួននៅទីផ្សារគោលដៅ។<br>ធាតុនៃកិច្ចទីផ្សារចម្រុះឬម៉ាឃិធីងចម្រុះជាទូទៅមានបួនគឺ ផលិតផល ( Product ) ថ្លៃ ( Price ) ទីកន្លែង ( Place ) និងការជំរុញផ្សព្វផ្សាយ ( Promotion ) ដែលហៅថា Pបួន "Four Ps"។ |
| ២- ម៉ាក្រូម៉ាឃិធីង/ ម៉ាក្រូកិច្ចទីផ្សារ<br>អ. macromarketing/<br>macro-marketing/<br>macro marketing<br>បារ. macromarketing ( m. )/<br>macro-marketing ( m. ) | សំណុំសកម្មភាពនិងដំណើរការកិច្ចទីផ្សារនៃទំនិញឬសេវាក្នុងកម្រិតប្រទេសឬសង្គមជាតិ ដោយមានការទទួលខុសត្រូវសង្គម។ |
| ៣- មីក្រូម៉ាឃិធីង<br>អ. micromarketing/<br>micro marketing<br>បារ. micromarketing/<br>micro marketing | សំណុំសកម្មភាពនិងដំណើរការកិច្ចទីផ្សាររបស់សហគ្រាសណាមួយ អំពីផលិតផលឬសេវារបស់ខ្លួនឆ្ពោះទៅក្រុមអតិថិជនជាក់លាក់។ |
| ៤- កិច្ចទីផ្សារឌីជីថល/<br>ឌីជីថលម៉ាឃិធីង<br>អ. digital marketing<br>បារ. marketing numérique ( m. ) | សំណុំសកម្មភាពកិច្ចទីផ្សារដើម្បីផ្សព្វផ្សាយអំពីផលិតផលដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ |
| ១២៥- កិច្ចទីផ្សារចល័ត/<br>ម៉ាឃិធីងចល័ត<br>អ. mobile marketing<br>បារ. marketing mobile | សំណុំសកម្មភាពកិច្ចទីផ្សារដើម្បីផ្សព្វផ្សាយអំពីផលិតផលដល់អតិថិជន តាមរយៈឧបករណ៍ចល័តរបស់អ្នកទទួល។ |

## ៤-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨

ថ្ងៃពុធ ១៥កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម បានប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការគីមីវិទ្យា និង រូបវិទ្យា បានចំនួន០៥ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- គីមីវិទ្យា/គីមី<br>អ. chemistry<br>បារ. chimie (f.) | វិទ្យាសាស្ត្រសិក្សាអំពីសមាសភាព ទម្រង់ លក្ខណៈ បម្រែបម្រួលនិងដំណើរប្រព្រឹត្តទៅរបស់រូបធាតុ។ |
| ២- អាស៊ីដ<br>អ. acid<br>បារ. acide (m.) | សមាសធាតុដែលផ្ដល់អ៊ីយ៉ុងអ៊ីដ្រូហ្សែន($H^+$) នៅពេលរលាយក្នុងទឹក។ |
| ៣- អុកស៊ីអាស៊ីដ<br>អ. oxyacid / oxoacid<br>បារ. oxyacide (m.) | អាស៊ីដដែលមានផ្ទុកអាតូមអុកស៊ីហ្សែនដូចជា អាស៊ីដស៊ុលហ្វួរិក ($H_2SO_4$) អាស៊ីដនីទ្រិក($HNO_3$)...។ |
| ៤- បាស<br>អ. base<br>បារ. base (f.) | សមាសធាតុដែលផ្ដល់អ៊ីយ៉ុងអ៊ីដ្រុកស៊ីដ($OH^-$) នៅពេលរលាយក្នុងទឹក។ |
| ៥- អុកស៊ីដ<br>អ. oxide<br>បារ. oxyde (m.) | សមាសធាតុដែលកើតពីប្រតិកម្មរវាងអុកស៊ីហ្សែននិងលោហៈឬអលោហៈ ដូចជាម៉ាញ៉េស្យូមអុកស៊ីដ($MgO$) ស៊ុលហ្វួអុកស៊ីដ($SO_2$)...។ |

## ៥-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

ថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ជួរ គារី បានដឹកនាំអង្គប្រជុំ ពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការអក្សរសិល្ប៍បានចំនួន០៦ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| **១- កាព្យល្បើក**<br>អ. fable poetry<br>បារ. poésie fabuleuse | កំណាព្យមួយបែបដែលកវីនិពន្ធលើកយកតួអង្គមនុស្ស សត្វ រុក្ខជាតិ វត្ថុ មកតាក់តែងជារឿងរ៉ាវខ្លីៗ ដែលបង្កប់នូវការរិះគន់ ដើម្បីអប់រំ ទូន្មាន ប្រៀនប្រដៅ ចរិយាធម៌ សីលធម៌ គុណធម៌...។<br>ឧទាហរណ៍ ល្បើកជុចនិងត្រី ល្បើកអក, ...។ |
| **២- កាព្យរូបារម្មណ៍**<br>អ. poetic imagery<br>បារ. images poétiques | រូបភាពក្នុងអារម្មណ៍ដែលកើតឡើងដោយពាក្យពេចន៍ សំនួនសេចក្ដីនៃអត្ថបទកំណាព្យ ដែលកវីនិពន្ធរចនារៀបចំឡើងទៅតាមសិល្បវិធីផ្សេងៗ។ |
| **៣- បទបថ្យាវត្ត** | ពាក្យកាព្យមួយប្រភេទ ដែលក្នុង១ល្បះមាន៤ឃ្លា ក្នុង១ឃ្លាមាន៨ព្យាង្គ។ គេប្រើបទនេះនៅក្នុងពិធីបុណ្យសាសនា(ព្រះពុទ្ធសាសនា)ឬសម្រាប់សម្ដែង ទុក្ខព្រួយ។ |

បទបថ្យាវត្តនេះ មានចំនួនព្យាង្គនិងចំនួនឃ្លាដូចបទពាក្យ៨ដែរ តែពុំមែន ជាបទពាក្យ៨ទេ ដោយមានចំណាប់ចួនឆ្លងឃ្លា និងឆ្លងល្បះខុសគ្នា។

គេសូត្របទនេះ ដោយទម្លាក់សំឡេងលើព្យាង្គទី២ ទី៤ និងទី៦ គ្រប់ឃ្លា។

- ចំណាប់ចួន

ចួនក្នុងល្បះ: -ព្យាង្គទី៨ ឃ្លាទី១ ចួននឹងព្យាង្គទី៤ ឃ្លាទី២
-ព្យាង្គទី៨ ឃ្លាទី២ ចួននឹងព្យាង្គទី៨ ឃ្លាទី៣
ចួននឹងព្យាង្គទី៤ ឃ្លាទី៤ ល្បះទី១។

ចួនឆ្លងល្បះ: -ព្យាង្គទី៨ ឃ្លាទី៤ ល្បះទី១ ចួននឹងព្យាង្គទី៨ ឃ្លាទី១
ចួននឹងព្យាង្គទី៤ ឃ្លាទី២ ល្បះទី២។

- គំនូសតាងបទបថ្យាវត្ត

①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧
①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧។
①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧
①②③④⑤⑥⑦⑧ ①②③④⑤⑥⑦⑧។

ឧទាហរណ៍

*-កម្ពុជារំដោះពីជ្រោះមរ**ណា*** *ប្រវត្តិសារ**តារ**ចារដោយលោ**ហិត***
*ប្រាប់អស់កម្ពុជនពីបទឧ**ក្រិដ្ឋ*** *ប៉ុលពតអាង**រិទ្ធិ**ព្រៃផ្សៃប្រូ**ស្សា**។*
*ខ្លួនមនុស្សចិត្តសត្វសាហាវអ**ស្វារ្យ*** *ចងចាប់ប្រ**ហារ**សម្លាប់ជាតិឯង*
*ខ្លាំងជាងអ៊ីត្លែដែលសកលស្ញែង* *សម្លាប់ឥតក្រែងឈាមឯងជាខ្មែរ*[១]*។*

**បរាភវសូត្រ**

***១-** វិនាសទី១ការស្អប់ធម៌**ត្រូវ*** *ទ្រុសសីលអា**ស្រូវ**ច្រើនធ្វើបំ**ពាន***
*ជាហេតុទាន់ហន់និងជាប្រ**ធាន*** *នាំសត្វឱ្យ**មាន**ក្តីវិនាស**ពិត**។*
***២-** វិនាសទី២គឺការគប់**មិត្ត*** *ដែលមានគំ**និត**អសប្បុរស*
*គ្មានមេត្តាធម៌នៅក្នុងខ្លួនសោះ* *ជាហេតុនាំឆ្ពោះវិនាសជាក់ស្តែង។*
***៣-** វិនាសទី៣នឹងលើកសម្តែង* *ពីអ្នកនោះឯងខ្ជិលពុំឧស្សាហ៍*
*ខឹងនិយាយច្រើនពុំខ្វល់ធ្វើការ* *នោះហើយគឺថាជាហេតុអន្តរធាន។*
*(…)*

---

[១] ក្រសួងអប់រំ : ***កំណាព្យខ្មែរ ភាគ១-២*** ភ្នំពេញ ឆ្នាំ១៩៨៤ ទំព័រ ៤៦។

| | |
|---|---|
| **៤- បទកាកគតិ** | ពាក្យកាព្យមួយប្រភេទដែលក្នុង១ល្បះមាន៧ឃ្លា ហើយក្នុង១ឃ្លាមាន ៤ព្យាង្គ។ ពាក្យកាកគតិ មានន័យថា ដំណើរក្អែកលោត ។<br>គេប្រើបទនេះសម្រាប់ពណ៌នាពីទីកន្លែង តួអង្គ ធម្មជាតិ ជាពិសេសប្រើក្នុងការផ្ដើមរឿង ពេលខ្លះក៏ប្រើក្នុងការសម្ដែងទុក្ខសោកផងដែរ។<br>គេសូត្របទនេះ ដោយទម្លាក់សំឡេងលើព្យាង្គទី២ និងទី៤គ្រប់ឃ្លា។<br>-ចំណាប់ចួនៈ<br>+ចួនក្នុងល្បះ ៖<br>-ព្យាង្គទី៤ ឃ្លាទី១ ចួននឹងព្យាង្គទី៤ ឃ្លាទី២<br>-ព្យាង្គទី៤ ឃ្លាទី៣ ចួននឹងព្យាង្គទី៤ឃ្លាទី៥ ចួននឹងព្យាង្គ៤ ឃ្លាទី៦<br>-ព្យាង្គទី៤ ឃ្លាទី៤ ចួននឹងព្យាង្គទី២ ឃ្លាទី៥ ល្បះទី១។<br>+ចួនឆ្លងល្បះ៖<br>-ព្យាង្គទី៤ ឃ្លាទី៧ ល្បះទី១ ចួននឹងព្យាង្គទី៤ ឃ្លាទី៣ ល្បះទី២។<br>-គំនូសតាងបទកាកគតិ<br><br>ឧទាហរណ៍៖<br>(...) ធ្លាប់បងបំពេ ព្រលឹងមាសមេ ដោះសក់រំសាយ<br>គេងលើទ្រូងបង ត្រកងកៀកកាយ កៀកកើយសប្បាយ<br>ស្រាប់តែព្រាត់ប្រាស។<br>ឥឡូវកៀកកើយ ព្រួយកល់ជាខ្នើយ គងដៃលើថ្ងាស<br>ដកធំដង្ហើម រឿងដើមដេរដាស រាវរកអាកាស<br>ក្នុងគុកស្នេហ៍ស្នង[2]។ (...) |

[2] កេង វ៉ាន់សាក់ : *គុកកាមកិលេស* ភ្នំពេញ ឆ្នាំ១៩៦៣ ទំព័រ ៩។

| | |
|---|---|
| **៥- បទកុជង្គលីលា** | ពាក្យកាព្យមួយប្រភេទដែលក្នុង១ល្បះមាន៣ឃ្លា ឃ្លាទី១ មាន៦ព្យាង្គ ឃ្លាទី២និងឃ្លាទី៣មាន៤ព្យាង្គ។ ពាក្យ កុជង្គលីលា មានន័យថា ដំណើរនាគ ។<br>គេប្រើបទនេះ សម្រាប់អប់រំទូន្មាន សម្រាប់រៀបរាប់ពីដំណើរចរលីលា រៀបរាប់ព្រៃព្រឹក្សា សរសើរសម្រស់ធម្មជាតិ...។<br>គេសូត្របទនេះ ដោយទម្លាក់សំឡេងលើព្យាង្គទី២ និង ព្យាង្គទី៤គ្រប់ឃ្លា។<br>-ចំណាប់ចួនៈ<br>ចួនក្នុងល្បះ -ព្យាង្គទី៦ ឃ្លាទី១ ចួននឹងព្យាង្គទី៤ ឃ្លាទី២ ល្បះទី១។<br>ចួនឆ្លងល្បះ -ព្យាង្គទី៤ ឃ្លាទី៣ ល្បះទី១ ចួននឹងព្យាង្គទី៦ ឃ្លាទី១ ចួននឹងព្យាង្គទី៤ ឃ្លាទី២ ល្បះទី២។<br>-គំនូសតាងបទកុជង្គលីលាៈ<br>①②③④⑤⑥ ①②③④ ①②③④។<br>①②③④⑤⑥ ①②③④ ①②③④។<br>ឧទាហរណ៍ៈ<br>(...)<br>ហៃកូនស្រីស្ងួនមាតា ចូរចាំរក្សា កុំភ្លេចស្មារតី។<br>ចូររករៀនយកច្បាប់ស្រី ឱ្យកោតខ្លាចប្ដី គម្លែងក្រឡា។<br>ធ្វើវត្តប្រតិបត្តិសោតណា ឱ្យនាងរក្សា ភ្នក់ភ្លើងទាំងបី។<br>ឱ្យកាត់ឱ្យគង់ប្រក្រតី សព្វថ្ងៃកុំបី ភ្លេចផ្ដុំឱ្យឆេះ[3]។<br>(...)<br>(...)<br>ស្ដេចចរនាំវរកល្យាណ ត្រាច់ក្នុងថ្មសាន ស្ងប់ស្ងាត់ជ្រងំ។<br>ដើរត្រាច់លុះលេចព្រៃភ្នំ វាលវែងធារធំ ដល់ឆ្នេរនទី។<br>ព្រះមហាក្សត្រាក្សត្រី សែនសោយសោកពី- លាបលន់រន្ធត់។<br>ចរចេរតាមឆ្នេរសមុទ្រ ពៀងពរាជបុត្រ ទាំងពីរអង្គា។ |

៣ ច្បាប់ស្រី ក្នុង«*ច្បាប់ផ្សេងៗ*» ភ្នំពេញ ការផ្សាយរបស់សមាគមសម្ដេច ជួន ណាត, បោះពុម្ពលើកទី១ ឆ្នាំ១៩៧៤ ទំព័រ ២២។

| | |
|---|---|
| | ឈរឈប់ក្រោមម្លប់ព្រឹក្សា ទៀងទូញថៃថា ឱគ្រានេះម្តង[4]។<br>(...) |
| **៦- បទពំនោល** | ពាក្យកាព្យមួយប្រភេទដែលក្នុង១ល្បះមាន៣ឃ្លា ឃ្លាទី១មាន៦ព្យាង្គ ឃ្លាទី២មាន៤ព្យាង្គ និងឃ្លាទី៣មាន៦ព្យាង្គ។<br>គេប្រើបទនេះ សម្រាប់រៀបរាប់ពីកំហឹងក្រេវក្រោធ សង្ស័ក សន្ធាប់ គំរាមកំហែង មហិទ្ធិឫទ្ធិរបស់អ្នកមានអំណាចខ្លាំងឬការអង្វរករ ការភ័យខ្លាចរបស់អ្នកទន់ខ្សោយពីជម្លោះចម្បាំងដែលមានសភាពក្តុងក្តាំង...។ ពេលខ្លះបទនេះ គេប្រើក្នុងការពោលពេលសម្តែងល្ខោន ដើម្បីឱ្យអ្នកសម្តែងធ្វើចលនា និង កាយវិការផ្សេងៗ។<br>គេសូត្របទនេះ ដោយទម្លាក់សំឡេងលើព្យាង្គទី២ និង ព្យាង្គទី៤។<br>-ចំណាប់ចួនៈ<br>ចួនក្នុងល្បះ -ព្យាង្គទី៦ ឃ្លាទី១ ចួននឹងព្យាង្គទី៤ ឃ្លា២ ល្បះទី១។<br>ចួនឆ្លងល្បះ -ព្យាង្គទី៦ ឃ្លាទី៣ ល្បះទី១ ចួននឹងព្យាង្គទី៦ ឃ្លាទី១ ល្បះទី២ ចួននឹងព្យាង្គទី៤ ឃ្លាទី២ ល្បះទី២។<br>-គំនូសតាងបទពំនោលៈ<br>①②③④⑤⑥ ①②③④ ①②③④⑤⑥។<br>①②③④⑤⑥ ①②③④ ①②③④⑤⑥។<br>ឧទាហរណ៍ៈ<br>(...)<br>ស្ទុះហោះផ្លោះហើរហិចផ្សង លាន់ឮគឹកកង រំពងនៃបក្សាខែង។<br>រារាំងបិទបាំងសូរ្យសែង សូរសឹងស្ងប់ស្ញែង អន្ធការមេឃមីរមេណ្ឌល[5]។<br>(...) |

[4] ឧកញ៉ាកោសាធិបតី កៅ ***រឿងក្រុងសុភមិត្រ*** ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥១៦ ទំព័រ ២១។

[៥] ព្រះបាទអង្គ ឌួង : ***រឿងកាកី*** ភ្នំពេញ ផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៦ ឆ្នាំ១៩៩៧ ទំព័រ១៨។

## ៦-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨

ថ្ងៃពុធ ៧រោច ខែអស្សុជ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម បានបន្តដឹកនាំប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការគីមីវិទ្យា និង រូបវិទ្យា បានចំនួន១៣ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- អុកស៊ីដអាស៊ីដ<br>អ. acidic oxide<br>បារ. oxyde acide ( m. ) | អុកស៊ីដដែលកើតពីប្រតិកម្មរវាងអុកស៊ីហ្សែនជាមួយអលោហៈ។<br>ឧ. $CO_2$, $SO_2$,...។ |
| ២- អុកស៊ីដបាស<br>អ. basic oxide<br>បារ. oxyde basique /<br>oxyde de base ( m. ) | អុកស៊ីដដែលកើតពីប្រតិកម្មរវាងអុកស៊ីហ្សែនជាមួយលោហៈ។<br>ឧ. MgO, $Na_2O$,...។ |
| ៣- អាតូម<br>អ. atom<br>បារ. atome ( m. ) | ភាគល្អិតតូចបំផុតនៃអង្គធាតុដែលសម្គាល់លក្ខណៈគីមីនៃអង្គធាតុនោះ។ |
| ៤- អ៊ីយ៉ុង<br>អ. ion<br>បារ. ion ( m. ) | អាតូមឬបណ្ដុំអាតូមដែលមានបន្ទុកអគ្គិសនី។ |
| ៥- អាញ៉ុង<br>អ. anion<br>បារ. anion ( m. ) | អ៊ីយ៉ុងដែលមានបន្ទុកអគ្គិសនីអវិជ្ជមាន។ |
| ៦- កាចុង<br>អ. cation<br>បារ. cation ( m. ) | អ៊ីយ៉ុងដែលមានបន្ទុកអគ្គិសនីវិជ្ជមាន។ |
| ៧- ណ្វៃយ៉ូ<br>អ. nucleus<br>បារ. noyau ( m. ) | ភាគល្អិតដែលមានបន្ទុកអគ្គិសនីវិជ្ជមានស្ថិតនៅចំកណ្ដាលនៃអាតូម។ |
| ៨- ប្រូតុង<br>អ. proton<br>បារ. proton ( m. ) | ភាគល្អិតដែលមានបន្ទុកអគ្គិសនីវិជ្ជមានស្ថិតនៅក្នុងណ្វៃយ៉ូនៃអាតូម។ |
| ៩- អេឡិចត្រុង | ភាគល្អិតដែលមានបន្ទុកអគ្គិសនីអវិជ្ជមានវិលជុំវិញណ្វៃយ៉ូនៃអាតូម។ |

| | |
|---|---|
| អ. electron<br>បារ. électron ( m. ) | |
| ១០- លេខអាតូម / លេខលំដាប់<br>អ. atomic number<br>បារ. numéro atomique ( m. ) | លេខដែលបញ្ជាក់ពីចំនួនប្រូតុងនៅក្នុងណ្វៃយ៉ូនៃអាតូមមួយបញ្ជាក់ពីទីតាំងរបស់ជាតុក្នុងតារាងខួបគីមី និងបញ្ជាក់ពីចំនួនអេឡិចត្រុងនៅជុំវិញណ្វៃយ៉ូរបស់អាតូមណឺត។ |
| ១១- ប្រតិកម្មគីមី<br>អ. chemical reaction<br>បារ. réaction chimique ( f. ) | លំនាំ/ដំណើរការដែលក្នុងនោះសម្ព័ន្ធរវាងអាតូមនៃជាតុឬសមាសជាតុត្រូវបានបំបែកដើម្បីបង្កើតជាសមាសជាតុថ្មី។ |
| ១២- ប្រតិកម្មបូក<br>អ. addition reaction<br>បារ. réaction d´addition ( f. ) | ប្រតិកម្មគីមីដែលបណ្ដាម៉ូលេគុលចូលផ្សំគ្នាដើម្បីបង្កើតជាម៉ូលេគុលសាំញ៉ាំជាង ( ជាទូទៅច្រើនប្រើក្នុងគីមីសរីរាង្គ )។ |
| ១៣- ប្រតិកម្មបន្សំ<br>អ. combination reaction<br>បារ. réaction de combinaison ( f. ) | ប្រតិកម្មគីមីដែលសារជាតុពីរឬច្រើនចូលផ្សំគ្នាដើម្បីបង្កើតជាសារជាតុមួយ ( ជាទូទៅច្រើនប្រើក្នុងគីមីអសរីរាង្គ )។ |